# បញ្ញត្តិ និងលក្ខខណ្ឌទូទៅនៃគណនីសន្សំកូនឆ្លាត

- គណនីកូនឆ្លាតអាចបើកម្នាក់ឯង ឬ រួមគ្នាដែលមានសមាជិកច្រើនបំផុតចំនួនពីរនាក់ក្នុងមួយគណនី។
- អតិថិជនតម្រូវឲ្យដាក់ប្រាក់អប្បបរមាចំនួន ១០ ដុល្លារអាមេរិក ឬ ៤០,០០០ រៀលពេលបើកគណនីដំបូង។ ចំនួនទឹកប្រាក់ដាក់លើកដំបូងរបស់លោកអ្នកនឹងត្រូវបានចាត់ទុកជាចំនួនប្រាក់សន្សំដែលអ្នកបានព្រមព្រៀងដាក់ជារៀងរាល់ខែ។
- ដើម្បីទទួលបានសេវាធានារ៉ាប់រង លោកអ្នកត្រូវធ្វើការដាក់ប្រាក់ជាប្រចាំខែយ៉ាងហោចណាស់ស្មើនឹងចំនួនទឹកប្រាក់នៃការដាក់សន្សំដំបូង។
- ក្នុងករណីអតិថិជនបិទគណនីក្នុងរយៈពេល ៥ ឆ្នាំដំបូង គិតចាប់ថ្ងៃបើកគណនី អតិថិជននឹងទទួលបានតែប្រាក់ដើមដែលបានដាក់សន្សំតែប៉ុណ្ណោះ។
- ក្នុងករណីដែលអតិថិជនខកខានក្នុងការដាក់ប្រាក់ប្រចាំខែច្រើនជាង ៥ ដងក្នុងគណនីណាមួយ នោះអតិថិជននឹងទទួលបានតែការធានារ៉ាប់រងលើអាយុជីវិតដែលបណ្តាលមកពីគ្រោះថ្នាក់ហូតដល់ ៣០០% នៃសមតុល្យដែលមាននៅក្នុងគណនីរបស់អតិថិជនគិតត្រឹមចុងខែមុន។
- ក្នុងករណីគណនីដែលបានបើកថ្មី និងមានសមតុល្យសូន្យដោយរាប់ចាប់ពីថ្ងៃបើកដំបូងរហូតដល់រយៈពេលធំជាង ៩០ថ្ងៃ នោះអតិថិជនយល់ព្រមអនុញ្ញាតឱ្យ អេ អឹម ខេ ធ្វើការបិទគណនីដោយស្វ័យប្រវត្តិដោយពុំចាំបាច់ធ្វើការជូនដំណឹងជាមុនឡើយ។

## ១. ព័ត៌មានអំពីសេវាធានារ៉ាប់រងភ្ជាប់ជាមួយគណនីកូនឆ្លាត

អេ អឹម ខេ ជាធនាគារដ៏ធំមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានសហការជាមួយក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេ ឡាយហ្វ៍ អ៊ីស្សូរិនស៍ (ខេមបូឌា) ម.ក ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងជាក្រុមហ៊ុនបុត្រសម្ព័ន្ធជាមួយរបស់ក្រុមហ៊ុនធានារ៉ាប់រង ហ្វតតេអ៊ិនស្សួរីនស៍ (ខេមបូឌា) ដែលជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខ និង ធំជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងអាយុជីវិតដល់អតិថិជនដែលជាម្ចាស់គណនីសន្សំកូនឆ្លាត។

## ២. ហេតុអ្វី អេ អឹម ខេ ផ្តល់ការធានារ៉ាប់រងអាយុជីវិតជូនដល់អតិថិជន?

ទន្ទឹមនឹងការសន្សំ អេ អឹម ខេ គិតគូរចង់ធានាភាពស្ងប់ក្នុងចិត្តដល់ក្រុមគ្រួសាររបស់លោកអ្នក ឬលោកអ្នកផ្ទាល់ដែលជាម្ចាស់គណនីកូនឆ្លាត អាចរក្សាស្ថានភាពហិរញ្ញវត្ថុ នៅខណៈពេលមានហេតុការគ្រោះថ្នាក់ណាមួយ ឬគ្រោះអកុសលណាមួយកើតឡើងចំពោះលោកអ្នក។ មានធានារ៉ាប់រងអាយុជីវិត លោកអ្នកនឹងអស់កង្វល់អំពីបញ្ហាមួយចំនួន ដែលអាចកើតមានឡើងដូចខាងក្រោម៖

- តើមានអ្វីនឹងអាចកើតឡើង ប្រសិនបើលោកអ្នកត្រូវពិការជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់ណាមួយ ឬជំងឺ និងមិនអាចបំពេញការងារ ឬប្រកបមុខរបរបន្តទៀត?
- តើនរណាជាអ្នកផ្តល់ហិរញ្ញទានដល់ក្រុមគ្រួសាររបស់លោកអ្នកប្រសិនបើលោកអ្នកត្រូវទទួលមរណភាពដោយសារជំងឺណាមួយ?

## ៣. តើអ្វីទៅជាការធានារ៉ាប់រងអាយុជីវិត?

ការធានារ៉ាប់រងអាយុជីវិត គឺជាការធានារ៉ាប់រងលើម្ចាស់គណនី ដែលបានបើកគណនីសន្សំកូនឆ្លាតជាមួយនឹង អេ អឹម ខេ ដោយផ្តល់សំណងជាទឹកប្រាក់នៅពេលដែលម្ចាស់គណនី៖

- ទទួលមរណភាពបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ
- ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ

## ៤. អត្ថប្រយោជន៍ធានារ៉ាប់រងអាយុជីវិតដែលភ្ជាប់មកជាមួយគណនីសន្សំកូនឆ្លាត

ទឹកប្រាក់ធានារ៉ាប់រងនឹងត្រូវផ្តល់ជូនម្ចាស់គណនីដូចមានរៀបរាប់ខាងក្រោម៖

**ក) គណនីកូនឆ្លាតឯកត្តជន (ម្ចាស់គណនីម្នាក់ឯង)**

- ចំពោះអតិថិជន (Per CID) ដែលមានគណនីកូនឆ្លាតឯកត្តជនមានទឹកប្រាក់សរុប ≤២,០០០.០០ ដុល្លារអាមេរិក អតិថិជននឹងទទួលបានការធានារ៉ាប់រងលើអាយុជីវិត ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីជំងឺ ឬគ្រោះថ្នាក់ហូតដល់ទឹកប្រាក់ចំនួន ៥,០០០.០០ ដុល្លារអាមេរិក។
- ចំពោះអតិថិជន (Per CID) ដែលគណនីកូនឆ្លាតឯកត្តជន មានទឹកប្រាក់សរុប >២,០០០.០០ ដុល្លារអាមេរិក អតិថិជននឹងទទួលបានការធានារ៉ាប់រងលើអាយុជីវិត ឬពិការភាពទាំងស្រុង និងជាចិន្ត្រៃយ៍ ដែលបណ្តាលមកពីជំងឺរហូតដល់ទឹកប្រាក់ចំនួន ៥,០០០.០០ ដុល្លារអាមេរិក ឬ បណ្តាលមកពីគ្រោះថ្នាក់ហូតដល់ ៣០០% នៃសមតុល្យសរុបដែលមាននៅក្នុងគណនីកូនឆ្លាតឯកត្តជនរបស់អតិថិជនទាំងអស់គិតត្រឹមចុងខែមុន ប៉ុន្តែសំណងធានារ៉ាប់រងជាអតិបរមាត្រូវបានកម្រិតត្រឹមចំនួន ២០០,០០០.០០ ដុល្លារអាមេរិកប៉ុណ្ណោះ។

**ខ) គណនីកូនឆ្លាតរួម (ម្ចាស់គណនីរួមគ្នាចំនួនពីរនាក់)**

- ចំពោះអតិថិជន (Per CID) ដែលមានគណនីកូនឆ្លាតរួម (និងគណនីកូនឆ្លាតឯកត្តជន ប្រសិនបើមាន) ដែលមានទឹកប្រាក់សរុប ≤២,០០០.០០ ដុល្លារអាមេរិក អតិថិជននឹងទទួលបានការធានារ៉ាប់រងលើអាយុជីវិត ឬពិការភាពទាំងស្រុង និងជាចិន្ត្រៃយ៍ ដែលបណ្តាលមកពីជំងឺ ឬគ្រោះថ្នាក់ហូតដល់ទឹកប្រាក់ចំនួន ២,៥០០.០០ ដុល្លារអាមេរិក។
- ចំពោះអតិថិជនម្នាក់ (Per CID) ដែលមានគណនីកូនឆ្លាតរួម (និងគណនីកូនឆ្លាតឯកត្តជន ប្រសិនបើមាន) មានទឹកប្រាក់សរុប >២,០០០.០០ ដុល្លារអាមេរិក អតិថិជននឹងទទួលបានការធានារ៉ាប់រងលើអាយុជីវិត ដែលបណ្តាលមកពីជំងឺរហូតដល់ទឹកប្រាក់ចំនួន ២,៥០០.០០ ដុល្លារអាមេរិក ក្នុងករណី

ដែលអតិថិជនរូបនោះជួបបញ្ហាដូចដែលមានចែងនៅក្នុងចំនុច៣ខាងលើ។ ដោយឡែកចំពោះការធានារ៉ាប់រងលើអាយុជីវិតដែលបណ្តាលមកពីគ្រោះថ្នាក់ ក្នុងករណីដែលសមាជិកគណនីណាម្នាក់ជួបបញ្ហាដូចដែលមានចែងនៅក្នុងចំណុច៣ខាងលើ អតិថិជនរូបនោះនឹងទទួលបានការទូទាត់សំណងដូចខាងក្រោម៖

- ចំពោះម្ចាស់គណនីដែលមានតែគណនីកូនឆ្លាតរួមជាមួយ អេ អឹម ខេ ម្ចាស់គណនីនឹងទទួលបានសំណងរហូតដល់ ១៥០%នៃសមតុល្យសរុបដែលមាននៅក្នុងគណនីកូនឆ្លាតរួមរបស់ខ្លួនទាំងអស់គិតត្រឹមចុងខែមុន ប៉ុន្តែសំណងធានារ៉ាប់រងជាអតិបរមាត្រូវបានកម្រិតត្រឹមចំនួន ២០០,០០០.០០ ដុល្លារអាមេរិក។
- ចំពោះម្ចាស់គណនីដែលមានមានគណនីកូនឆ្លាតរួមផង និងគណនីកូនឆ្លាតឯកត្តជនផង ម្ចាស់គណនីនឹងទទួលបានសំណងរហូតដល់ ១៥០% នៃសមតុល្យសរុបដែលមាននៅក្នុងគណនីកូនឆ្លាតរួមរបស់ខ្លួនទាំងអស់គិតត្រឹមចុងខែមុន និង៣០០% នៃសមតុល្យសរុបដែលមាននៅក្នុងគណនីកូនឆ្លាតឯកត្តជនរបស់ខ្លួនទាំងអស់គិតត្រឹមចុងខែមុន ប៉ុន្តែសំណងធានារ៉ាប់រងជាអតិបរមាត្រូវបានកម្រិតត្រឹមចំនួន ២០០,០០០ ដុល្លារអាមេរិក។

**សម្គាល់៖** ចំពោះម្ចាស់គណនីណាម្នាក់ដែលមានគណនីកូនឆ្លាតឯកត្តជនផង និងគណនីកូនឆ្លាតរួមផងជាមួយ អេ អឹម ខេ អត្ថប្រយោជន៍នៃសេវាធានារ៉ាប់រងនឹងត្រូវបានផ្តល់ជូនតាមលក្ខខណ្ឌនៅក្នុងចំណុច "ខ" គណនីកូនឆ្លាតរួម (ម្ចាស់គណនីរួមគ្នាចំនួនពីរនាក់)" តែប៉ុណ្ណោះ។

## ៥. មរណភាពបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ

ប្រសិនបើម្ចាស់គណនីដែលជាអ្នកត្រូវបានធានារ៉ាប់រងអាយុជីវិតទទួលមរណភាពបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺក្នុងអំឡុងពេលនៃការធានារ៉ាប់រង និងក្រោយពីទទួលបានភស្តុតាងត្រឹមត្រូវពេញលេញ និងសមស្រប ទឹកប្រាក់ត្រូវបានធានារ៉ាប់រងសម្រាប់អត្ថប្រយោជន៍មរណភាពបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺដូចបានរៀបរាប់ខាងលើនឹងត្រូវផ្តល់ជូនអ្នកទទួលផលស្របច្បាប់របស់ម្ចាស់គណនី។

## ៦. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ

ពិការភាពទាំងស្រុង និង ជាអចិន្ត្រៃយ៍មានន័យថាជាភាពពិការដែលបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺដែលកើតឡើងក្នុងអំឡុងនៃការធានារ៉ាប់រង និងដែលរារាំងទាំងស្រុងចំពោះអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតពីលទ្ធភាពបំពេញអាជីវកម្មមុខរបរណាមួយនិង/ឬការងារណាមួយ ដើម្បីអាចទទួលបានប្រាក់ចំណេញ ឬប្រាក់ខែ ហើយពិការភាពនេះនៅបន្តឥតដាច់ ក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ខែជាប់ៗគ្នា។

ប្រសិនបើម្ចាស់គណនីដែលជាអ្នកត្រូវបានធានារ៉ាប់រងអាយុជីវិតក្លាយជាពិការទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ ក្នុងអំឡុងពេលនៃការធានារ៉ាប់រង និងក្រោយពីទទួលបានភស្តុតាងត្រឹមត្រូវ ពេញលេញ និងសមស្រប ទឹកប្រាក់ត្រូវ បានធានារ៉ាប់រងដូចបានរៀបរាប់ខាងលើនឹងត្រូវផ្តល់ជូនម្ចាស់គណនីដែលជាអ្នកត្រូវបានធានារ៉ាប់រងអាយុជីវិត។

ត្រូវចាត់ទុកជាពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ប្រសិនអ្នកដែលត្រូវធានារ៉ាប់រងបាត់បង់អវៈយវៈដូចខាងក្រោម៖

- ភ្នែកទាំងពីរមិនអាចមើលឃើញបានទាំងស្រុង និងជាអចិន្ត្រៃយ៍
- បាត់បង់ដៃទាំងសងខាង (ចាប់ពីកំភួនដៃឡើង)
- បាត់បង់ជើងទាំងសងខាង (ចាប់ពីក្បាលជង្គង់ឡើង)
- បាត់បង់ដៃម្ខាង (ចាប់ពីកំភួនដៃឡើង) និងបាត់បង់ជើងម្ខាង (ចាប់ពីក្បាលជង្គង់ឡើង)
- ភ្នែកម្ខាងមិនអាចមើលឃើញបានទាំងស្រុង និងបាត់បង់ដៃម្ខាង (ចាប់ពីកំភួនដៃឡើង) ឬបាត់បង់ជើងម្ខាង (ចាប់ពីក្បាលជង្គង់ឡើង) ពិការភាពមានន័យថាដៃ(ចាប់ពីកំភួនដៃឡើង)ឬជើង(ចាប់ពីក្បាលជង្គង់ឡើង)មិនអាចព្យាបាលឱ្យបានដូចដើមទាំងស្រុង។

## ៧. ករណីមិនធានា

**ចំពោះមរណភាព**

1. ការធ្វើអត្តឃាតរបស់អ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតក្នុងរយៈពេល២ឆ្នាំគិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃការធានារ៉ាប់រង។
2. មរណភាពដោយការប្រព្រឹត្ត ឬប៉ុនប៉ងធ្វើបទល្មើសព្រហ្មទណ្ឌ។
3. ដំណាក់កាលចុងក្រោយនៃការខូចតម្រងនោម៖ ត្រូវបានបង្ហាញឡើងពីការខ្សោយរ៉ាំរ៉ៃក្នុងការបំពេញមុខងាររបស់តម្រងនោមទាំងសង្ខាង ហើយមិនអាចព្យាបាលជាសះស្បើយបានឡើងវិញ ឬ តម្រូវឱ្យធ្វើការលាងឈាមជាប់ជាប្រចាំ (ច្រើនជាង២ដងក្នុង១សប្តាហ៍) ឬ តម្រូវចាំបាច់ត្រូវធ្វើការវះកាត់ផ្លាស់ប្តូរតម្រងនោម។
4. ជំងឺមហារីកគ្រប់ប្រភេទ ឬ មហារីកគ្រាប់ឈាម៖ រាល់ដុំសាច់ទាំងឡាយណា ដែលត្រូវបានធ្វើរោគវិនិច្ឆ័យឃើញវិជ្ជមាននៅកោសិកាមហារីក(ដុំសាច់កាច) ដោយមានការបញ្ជាក់ពីជាលិកាសាស្ត្រ (Histological) និងកំណត់លក្ខណៈដោយការលូតលាស់មិនអាចគ្រប់គ្រងបាន(uncontrolled growth )នៃកោសិកាមហារីកនិងការរាតត្បាត/រាលដាលលើជាលិកាធម្មតា ឬ សិរាង្គក្បែរទីតាំងដើមនៃកោសិកាមហារីក។ ពាក្យថាដុំសាច់មហារីក(ដុំសាច់កាច) រួមបញ្ចូលផងដែរនូវ ជំងឺមហារីកគ្រាប់ឈាម មហារីកជាលិកាប្រព័ន្ធទឹករងៃ និងមហារីកឆ្អឹង ឬ សរសៃសាច់ដុំ។

**ចំពោះពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍**

1. ការធ្វើអត្តឃាត ការប៉ុនប៉ងធ្វើអត្តឃាត ឬការធ្វើឲ្យមានរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

2. មានផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ ឬជំងឺទាំងឡាយណា ពាក់ព័ន្ធនិងជំងឺអេដស៍។
3. ករណីសង្គ្រាម (ប្រកាស ឬមិនប្រកាសក្តី) ការឈ្លានពានសកម្មភាពរបស់សត្រូវបរទេស អំពើភេរវកម្ម សង្គ្រាមស៊ីវិល សកម្មភាពឧទ្ទាម បដិវត្តន៍ ការងើបបះបោរ កូដកម្ម កុបកម្ម និងចលាចលសង្គមដែលប្រឆាំងនឹងរដ្ឋាភិបាល។
4. ករណីអ្នកដែលត្រូវបានធានាអាយុជីវិតប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឬខណៈពេលដែលកំពុងត្រូវបានតាមចាប់ខ្លួន ឬកំពុងត្រូវបានឃាត់ខ្លួន ឬរត់គេចពីការចាប់ខ្លួន។
5. ករណីអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតឡើងជិះ ឬធ្វើដំណើរតាមយន្តហោះដែលគ្មានអាជ្ញាប័ណ្ណដឹកអ្នកដំណើរ ឬមិនមែនជាយន្តហោះប្រភេទដឹកអ្នកដំណើរ។
6. ករណីបំពេញភារកិច្ចជាអ្នកបំរើការនៅលើយន្តហោះ ឬអ្នកបើកបរយន្តហោះណាមួយ។
7. ករណីអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតបំពេញមុខងារជាកងកម្លាំងប្រដាប់អាវុធ នគរបាល ឬ អ្នកស្ម័គ្រចិត្តដែលចូលរួមក្នុងសង្គ្រាម ឬ សកម្មភាពបង្ក្រាបបទឧក្រិដ្ឋណាមួយ។
8. ករណីបាត់បង់អវៈយវៈ ពិការភាព ការបាត់បង់ ការរងរបួស ឬជំងឺ ដែលកើតឡើងមុនពេល អ្នកដែលត្រូវបានធានាអាយុជីវិតត្រូវបានអនុញ្ញាតទទួលបានការធានារ៉ាប់រងក្រោមបណ្ណសន្យារ៉ាប់រង ស្របតាមគោលការណ៍វាយតម្លៃហានិភ័យធានារ៉ាប់រង ឬគោលការណ៍នៃការជ្រើសរើសហានិភ័យរបស់ក្រុមហ៊ុន។
9. ករណីមានរបួសដែលកើតឡើងដោយសារឥទ្ធិពលនៃការប្រើប្រាស់គ្រឿងស្រវឹងដែលមានកម្រិតជាតិអាល់កុលត្រូវបានហាមឃាត់ដោយច្បាប់ ឬការប្រើប្រាស់សារធាតុញៀនណាមួយ ដែលបង្កឲ្យមានគ្រោះថ្នាក់រហូត និងមិនអាចគ្រប់គ្រងអារម្មណ៍បាន។

## ៨. លក្ខខណ្ឌទទួលបានផលប្រយោជន៍នៃការធានារ៉ាប់រង

អ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតត្រូវមាន៖

- គណនីកូនឆ្លាតរួម ឬឯកត្តជនដែលមានសុពលភាព ស្របតាមគោលនយោបាយរបស់អេ អឹម ខេ។
- អាយុត្រូវបានធានារ៉ាប់រង៖
  - <u>ក្រោមអត្ថប្រយោជន៍ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងមរណភាពបណ្តាលមកពីគ្រោះថ្នាក់</u>៖ អ្នកដែលត្រូវបានធានារ៉ាប់រងត្រូវមានអាយុចន្លោះពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ៦៥ (ហុកសិបប្រាំ) ឆ្នាំ។
  - <u>ក្រោមអត្ថប្រយោជន៍ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងមរណភាពបណ្តាលមកពីជំងឺ</u>៖ អ្នកដែលត្រូវបានធានារ៉ាប់រងត្រូវមានអាយុចន្លោះពី ១៥ (ដប់ប្រាំ) ឆ្នាំ ដល់ ៥០ (ហាសិប) ឆ្នាំ។

## ៩. លក្ខខណ្ឌនៃការទាមទារសំណងធានារ៉ាប់រង

**មរណភាពបណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ**

ក្នុងករណីម្ចាស់គណនីដែលជាអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាព អ្នកទទួលផលស្របច្បាប់របស់ម្ចាស់គណនីដែលជាអ្នកដែលត្រូវបានធានារ៉ាប់រងត្រូវ៖

- ជូនដំណឹងមកកាន់អេ អឹម ខេ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន និងបញ្ជាក់អត្តសញ្ញាណខ្លួនជាអ្នកទទួលផលស្របច្បាប់របស់ម្ចាស់គណនីដែលជាអ្នកត្រូវបានធានារ៉ាប់រងអាយុជីវិត។
- ផ្តល់មកជាមួយឯកសារសម្គាល់អត្តសញ្ញាណរបស់ខ្លួន ឯកសារសម្គាល់អត្តសញ្ញាណរបស់អ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិត និងឯកសារបញ្ជាក់អំពីទំនាក់ទំនងរបស់អ្នកទទួលផលស្របច្បាប់ និងម្ចាស់គណនីដែលជាអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិត សេចក្តីចម្លងលិខិតមរណភាពច្បាប់ដើមរបស់អ្នកដែលត្រូវបានធានារ៉ាប់រង របាយការណ៍ ឬវិញ្ញាបនបត្រវេជ្ជសាស្ត្រ ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌសុខភាព និង/ឬការព្យាបាលរបស់អ្នកដែលត្រូវបានធានារ៉ាប់រង និងរបាយការណ៍ប៉ូលីស (ប្រសិនមរណភាពពាក់ព័ន្ធនឹងគ្រោះថ្នាក់)។

**ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បណ្តាលមកពីគ្រោះថ្នាក់ ឬជំងឺ**

ក្នុងករណីអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតក្លាយជាពិការទាំងស្រុង និងជាអចិន្ត្រៃយ៍ ម្ចាស់គណនីដែលជាអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិតត្រូវ៖

- ជូនដំណឹងមកកាន់អេ អឹម ខេ ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន
- ផ្តល់មកជាមួយឯកសារសម្គាល់អត្តសញ្ញាណរបស់ខ្លួន របាយការណ៍ ឬវិញ្ញាបនបត្រវេជ្ជសាស្ត្រ ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌសុខភាព និង/ឬការព្យាបាលរបស់អ្នកដែលត្រូវបានធានារ៉ាប់រង និងរបាយការណ៍ប៉ូលីស (ប្រសិនបើពិការភាពពាក់ព័ន្ធនឹងគ្រោះថ្នាក់)។

<u>កំណត់សម្គាល់ចំពោះឯកសារគាំទ្រការទាមទារសំណង</u>៖ ក្នុងករណីមានតម្រូវការលើឯកសារគាំទ្របន្ថែមណាមួយផ្សេងទៀត អេ អឹម ខេ នឹងធ្វើការជូនដំណឹង និងស្នើសុំក្រោយពីបានដាក់ឯកសារខាងលើ។

## ១០. គោលការណ៍នៃការដោះស្រាយសំណងធានារ៉ាប់រង

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត នឹងធ្វើការទូទាត់សំណងឱ្យបានឆាប់បំផុត ក្រោយពីក្រុមហ៊ុនបានទទួលឯកសារពេញលេញ គ្រប់គ្រាន់ និងសមស្របសម្រាប់ការទាមទារសំណង។

## ១១. កំណត់សម្គាល់ចំពោះការទាមទារសំណង

- រាល់សំណងដែលបានទទួលដោយអ្នកដែលត្រូវបានធានារ៉ាប់រងអាយុជីវិត ឬ អ្នកទទួលផលរបស់អ្នកត្រូវបានធានារ៉ាប់រងអាយុជីវិត នឹងរំលត់កាតព្វកិច្ចទូទាត់សំណងក្រោមបណ្ណសន្យារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ចំពោះអ្នកត្រូវបានធានារ៉ាប់រងអាយុជីវិតរួចការធានារ៉ាប់រងនឹងត្រូវបញ្ចប់
- ក្រុមហ៊ុនធានារ៉ាប់រងរក្សាសិទ្ធិក្នុងការកែប្រែវិធាននៃការដោះស្រាយសំណងដោយមិនមានការជូនដំណឹង។
- អ្នកត្រូវបានធានារ៉ាប់រងអាយុជីវិត ឬអ្នកទទួលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ក្នុងករណីបន្លំ ឬផ្តល់ព័ត៌មានមិនពិតណាមួយដោយចេតនា ឬអចេតនា ដើម្បីទទួលបានសំណងពីក្រុមហ៊ុនធានារ៉ាប់រង។

## ១២. ការរក្សាសិទ្ធិរបស់អេ អឹម ខេ

- អេ អឹម ខេ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរដៃគូធានារ៉ាប់រង ឬកែប្រែលក្ខខណ្ឌផ្សេងៗដូចបានរៀបរាប់ខាងលើ។

## ១៣. ការឯកភាពរបស់អតិថិជន

- អតិថិជនបានអាន និងយល់អំពីបញ្ញត្តិ និងលក្ខខណ្ឌនៃគណនីកូនឆ្លាត លក្ខខណ្ឌធានារ៉ាប់រងផ្សេងៗដែលមានចែងនៅក្នុងសៀវភៅព័ត៌មានសេវាធានារ៉ាប់រងអាយុជីវិតដែលមានភ្ជាប់ជាមួយគណនីកូនឆ្លាត និងគ្រប់លក្ខខណ្ឌដែលមានចែងខាងលើ។